# ផលិតកម្ម និង ការថែបំប៉នកូនត្រីឆ្ពង់



## កម្មវិធីបណ្ដុះបណ្ដាលសម្រាប់មន្ត្រីផ្សព្វផ្សាយ និង កសិករ

# មាតិកា

I. ការពេញវ័យរបស់មេពូជ ការពងកូន និងការភ្ញាស់ពងផ្សំកំណើត
II. ការថែបំប៉នកូនត្រីម្សៅ
III. ការផ្សុំកូនត្រីពូជ
IV. ការគ្រប់គ្រងសុខភាពត្រី

# ភាពពេញវ័យរបស់មេពូជការពងកូននិងការភ្ញាស់ពង ផ្សាំកំណើត

# ការជ្រើសរើសពូជ និងការថែបំប៉ន

- ជ្រើសរើសមេពូជដែលមានទំហំសមស្រម(ត្រីឈ្មោលទម្ងន់5-7Kg និងត្រីញីទម្ងន់7-10kg)
- មេពូជញីនិងឈ្មោលត្រូវថែបំប៉ននៅក្នុងអាងផ្សេងគ្នា
- ការប្តូរទឹកប្រើតាមវិធីសាស្រ្តបង្ហូរចូលនិងបង្ហូរចេញ ជាមួយអត្រាប្តូរ ទឹក100%
- ដង់ស៊ីតេស្តុក1kg/m$^3$
- ផ្តល់ត្រីបង្កក និង មឹកជាមួយអត្រាផ្តល់ចំណី5% នៃទម្ងន់ត្រីសរុប (1-2 ថ្ងៃម្តង)



ប្រព័ន្ធផ្លាស់ប្តូរទឹកក្នុងអាងមេពូជ



ចំណីរបស់ត្រីមេពូជ

# ការលើកដាក់ត្រីមេពូជ

ត្រីមេពូជងាយនឹងទទួលរងភាពស្រេ្តស នៅពេលចាប់ត្រីត្រូវធ្វើដោយប្រុងប្រយ័ត្ន៖

- បង្ហូរទឹកនៅក្នុងអាងអោយស្មើកំពស់ខ្លួនត្រី
- ប្រើភួយឬកន្ទ្រេងធំដើម្បីចាប់ត្រីមេពូជ
- សណ្តំត្រីអោយសន្លប់មុនពេលចាក់អ័រម៉ូន



ត្រីមេពូជបន្ទាប់ពីសណ្តំ





ចាប់ត្រីមេពូជថ្នមៗដោយប្រើភួយឬកន្ទ្រេងធំៗ

# ការសណ្តំត្រីមេពូជ

- សណ្តំត្រីនៅក្នុងទឹកសមុទ្រត្រូវប្រើម្សៅផ្កាច័ន្ទ(0.1g/L)
- ចាំរហូតដល់ត្រីលែងមានចលនា(4-10នាទី)
- ដំណើរការចាក់អ័រម៉ូន ត្រីមេពូជមិនត្រូវលើសពី15នាទី
- មុនពេលប្រលែងត្រីមេពូជចូលទៅក្នុងអាងត្រូវធ្វើអោយត្រីមេពូជដឹងខ្លួនជាមុនសិន

» ការសណ្តំត្រី




➢ ការធ្វើអោយត្រីដឹងខ្លួនវិញ



# ការផលិតកូនត្រីឆ្លង់(ពាក់កណ្តាលសិប្បនិម្មិត)

- ជាទូទៅត្រីឆ្លង់ពងកូន2-3ថ្ងៃមុនថ្ងៃពេញបូរណ៌មីស្ទើរតែរៀងរាល់ខែ
- ត្រូវពិនិត្យមើលគ្រាប់ពង2-3ថ្ងៃមុនថ្ងៃពេញបូរណ៌មីដោយប្រើទុយោតូច(Cannulation)
- ត្រីញីដែលមានគ្រាប់ពងទំហំ > 0.4mm ច្រើនជាង 50% ទើបចាក់អ័រម៉ូនបាន
- ស្មើមរបស់ត្រីឈ្មោលត្រូវមានចលនាលើស3នាទី នៅពេលត្រូវទឹកសមុទ្រ
- សមាមាត្រត្រីឆ្លង់ញីឈ្មោលសម្រាប់បង្កាត់គឺ 2:4 (ត្រីញី2ក្បាល ត្រីឈ្មោល4ក្បាល)

# ការពិនិត្យទំហំគ្រាប់ពង និងចលនាស្ពើម

- ទីតាំងរន្ធបន្តពូជរបស់ត្រីឆ្តង់
- ការពិនិត្យមើលទំហំគ្រាប់ពង > 0.4mm
- ការពិនិត្យមើលគ្រាប់ពងដោយប្រើទុយោតូច(Cannulation)
- ការពិនិត្យមើលចលនារបស់ស្ពើម










# ការជម្រុញកន្សោមពងនិងស្មើម

- ❖ ទីតាំងចាក់អ័រម៉ូនចាក់នៅក្នុងសាច់ដុំក្រោមព្រុយខ្នង
- ❖ ចាក់ក្នុងសាច់ដុំ ម្ជុលត្រូវចាក់ក្នុងចន្លោះស្រកាពីកន្ទុយទៅក្បាល
- ❖ HCG (Human Chorionic Gonadotropin)

  - ត្រីញី: 500ខ្នាតអន្តជាតិ(IU)/Kg fish
  - ត្រីឈ្មោល: 250 IU / Kg fish

- ❖ ឧទាហរណ៍ ស្ដីពីពេលវេលានៃការបង្កាត់

  - ចាក់ថ្នាំត្រីនៅពេលព្រឹកម៉ោង 9:00
  - ត្រីនឹងទម្លាក់ពងក្រោយរយៈពេល 36 ម៉ោងនៃការចាក់អ័រម៉ូន ក្រោមសីតុណ្ហភាព28អង្សាសេ (9:00ល្ងាច បន្ទាប់ពីចាក់រួច)













មើលពីលើ



ពំនុះកាត់ទទឹង

# ការពងកូននិងការប្រមូលគ្រាប់ពង

- ប្រមូលពងដោយប្រើស្បៃនីឡុងដែលមានក្រឡា200-500μm
- ពងរបស់ត្រីឆ្លងជាប្រភេទពងអណ្តែតលើផ្ទៃទឹក រួចហូរតាមបំពង់បង្ហូរទឹកចូលទៅក្នុងស្បៃត្រងពង



ស្បៃប្រមូលពងនៅ MARDeC



# ការប្រមូលគ្រាប់ពង ថ្លឹង និងភ្ញាស់

- ប្រមូលពងពីស្បៃបន្ទាប់ពីផ្សំកំណើតបាន6ម៉ោង(ដំណាក់កាលអំប្រីយ៉ុង)
- ថ្លឹងគ្រាប់ពងសើម(1Kg ប្រមាណ2000000គ្រាប់)
- ដង់ស៊ីតេភ្ញាស់500000គ្រាប់/m³
- ខ្យល់ត្រូវបានគេប្រើក្នុងកំឡុងពេលភ្ញាស់ ចំណែកទឹកក៏ត្រូវបានគេបញ្ចូលជាប់រហូត



# ការភ្ញាស់ពងនិងការញាស់ជាកូនត្រីម៉ៅ

- ពងផ្សាំកំណើតនិងកូនត្រីទើបញាស់ ត្រូវបានគេរក្សាក្នុងអាងភ្ញាស់ប្រហែល40ម៉ោង (រហូតដល់អស់អាហារបម្រុង)
- ខ្យល់ត្រូវបានគេបើកតិចៗ



# ការថែបំប៉នកូនត្រីម៉ៀ

# គោលការណ៍នៅក្នុងផលិតកម្មត្រីសមុទ្រ



# មីក្រូសារ៉ាយចំណីរបស់រ៉ូទីហ្វឺ (Rotifer)

- ក្លរ៉េឡាខាប់ចំណុះ20L(នាំចូលពីប្រទេសជប៉ុន)
  - ក្លរ៉េឡាខាប់(ទឹកសាប)ចំណុះ20L ស្មើនឹងក្លរ៉េឡាចិញ្ចឹមក្នុងអាង55$m^3$
  - ប្រើសម្រាប់ចិញ្ចឹមរ៉ូទីហ្វឺប្រពលវប្បកម្ម ក្នុងអាងតូចរយៈពេលខ្លី
- ការចិញ្ចឹមមីក្រូសារ៉ាយ តេត្រាសែលមីស(Trlraselmis)
  - ចិញ្ចឹមក្នុងកែវថ្លា ដោយប្រើខ្យល់ខ្លាំង និងពន្លឺខ្លាំង5,000 lux
  - តេត្រាសែលមីស ប្រើសម្រាប់ចំណីរ៉ូទីហ្វឺ និងដាក់ក្នុងអាងកូនត្រីជាចំណី សម្រាប់រ៉ូទីហ្វឺដែលនៅសល់ក្នុងអាង











# ការចិញ្ចឹមរ៉ូទីហ្វឺតាមបែបប្រពលវប្បកម្ម

- រ៉ូទីហ្វឺ(Brachionus rotundiformis) ជាចំណីរបស់កូនត្រី
- ក្លរ៉ែឡាខាប់(Chlorella) ជាចំណីរបស់រ៉ូទីហ្វឺ






# ចំណីកូនត្រីផ្តល់ទៅតាមដំណាក់កាល






ចំណីម្សៅសម្រាប់កូនត្រី

# ការផ្តល់ចំណីកូនត្រីតាមអាយុកាល

- អាយុ 2-7 ថ្ងៃៈ អោយស៊ីរ៉ូទីហ្វ៊ី និង មីក្រូសារ៉ាយ ជាចំណី
- អាយុ 8-12 ថ្ងៃៈ អោយស៊ីរ៉ូទីហ្វ៊ី មីក្រូសារ៉ាយ និងចំណីម៉្សៅ ជាចំណី
- អាយុ 13-20 ថ្ងៃៈ អោយស៊ីរ៉ូទីហ្វ៊ី អាតេមៀ និងចំណីម៉្សៅ ជាចំណី
- អាយុ 21 ថ្ងៃឡើងទៅអោយស៊ីតែចំណីម៉្សៅទេ











ពងអាតេមៀនិងអាតេមៀ

# ការប្រមូលកូនត្រី និងការរែងកូនត្រីលើកទី១

- ការប្រមូលកូនត្រីដែលមានអាយុមួយខែ
- ការរែងកូនត្រី
- ឈិបប្រមូលកូនត្រី
- ឧបករណ៏រែងកូនត្រី











ពេលកូនត្រីអាយុមួយខែ ចាប់ផ្ដើមមានទំហំផ្សេងៗគ្នា ដើម្បីជៀសវាងការស៊ីគ្នា ចាំបាច់ត្រូវតែរែងវាទៅតាមទំហំផ្សេងៗគ្នា

# ការរែងកូនត្រី

ការថៃបំប៉នប្រភេទកូនត្រីស៊ីសាច់ ការរែងគឺជាសកម្មភាពដ៏សំខាន់ដើម្បីកាត់បន្ថយការស៊ីគ្នា



ការរែងកូនត្រីឆ្តង់អាយុ ១ខែ



កូនត្រីឆ្តង់ស៊ីគ្នា



# ឧបករណ៍សម្រាប់រែងកូនត្រី

## ឧបករណ៍



ឧបករណ៍រែងត្រីប្រើនៅ MARDeC ឆ្នាំ 2012 ដល់2013



ឧបករណ៍រែងត្រីប្រើនៅ MARDeC ឆ្នាំ 2013 ដល់2016



ឧបករណ៍រែងត្រីប្រើនៅ MARDeC ឆ្នាំ 2016 ដល់2018



ឧបករណ៍រែងត្រីប្រើនៅ MARDeC ឆ្នាំ 2018 ដល់ បច្ចុប្បន្ន



ឧបករណ៍វែងត្រីប្រើនៅ គម្រោង HARVEST project, USAID



ឧបករណ៍វែងត្រីប្រើនៅប្រទេសចិន





ការរែងកូនត្រីតុកែនៅកោះបាលី ប្រទេសឥណ្ឌូនេស៊ី

# ទំនាក់ទំនងរវាងទំហំឧបករណ៍វែងត្រី
# ប្រវែង និងកម្ពស់ខ្លួនត្រី

| ទំហំឧបករណ៍វែងត្រី (mm) | ប្រវែងសរុប (mm) | កម្ពស់ខ្លួន (mm) |
|---|---|---|
| 3 | 11.86 | 3.29 |
| 5 | 17.00 | 4.73 |
| 8 | 22.00 | 6.28 |
| 10 | 29.46 | 8.77 |
| 12 | 35.00 | 10.21 |
| 14 | 45.50 | 13.06 |



# ការប៉ាន់ប្រមាណចំនួនកូនត្រី

- ដំបូងត្រូវរាប់កូនត្រី500 ឬ1000 ក្បាលក្នុងមួយចានដើម្បីធ្វើជាគម្រូ
- បន្ទាប់មក ដួសកូនត្រីដាក់ក្នុងចានដោយមិនចាំបាច់រាប់(ប្រៀបធៀបជាមួយចានគម្រូ)





# ការផ្សាំកូនត្រីពូជ

# ការផ្សាំកូនត្រីក្នុងអាង

## សម្ភារៈ

- អាងផ្សាំកូនត្រី
- អាងជ័រឬអាងស៊ីម៉ង់ត៍
- ម៉ូទ័រខ្យល់
- បំពង់ទីប

## ឧបករណ៍

- ម៉ូទ័របូមទឹក
- ឧបករណ៍វាស់កំហាប់អំបិល
- ឧបករណ៍ចម្រោះដោយអេប៉ុង



# ប្រព័ន្ធផ្គត់ផ្គង់ទឹកក្នុងរោងផ្ញាំកូនត្រី



# ទំហំចំណី




ទំហំចំណីមានការកើនឡើងស្របគ្នាជាមួយកំណើនទំហំរបស់កូនត្រី

# អត្រានិងចំនួនដងនៃការផ្តល់ចំណី

- ការផ្តល់ចំណីបន្តិចម្តងៗ តែត្រូវផ្តល់អោយបានច្រើនដង(2-3ម៉ោងម្តង)
- ជៀសវាងការផ្តល់ចំណីសល់ច្រើននៅបាតអាង
- ផ្តល់ចំណីរហូតដល់ត្រីឆ្អែត



# ឧបករណ៍ចម្រោះទឹកក្នុងអាង









ឧបករណ៍ចម្រោះទឹកដោយប្រើខ្យល់ មានមុខងាររូបនិងជីវសាស្ត្រក្នុងការច្រោះទឹកក្នុងអាង
វាធ្វើពីបំពង់ទីបជ័រ និងអេប៉ុង

# ការផ្សាំកូនត្រីក្នុងស្រះ



ស៊ីង
(គ្មានសាច់ម៉ុងនៅបាត)

ហាប៉ា
(មានសាច់ម៉ុងនៅបាត)

បែបណ្តែត
(អាចផ្លាស់ទីបាន)

# ការផ្ទុំកូនត្រីនៅក្នុងស្រះ

- កូនត្រីដែលចេះស៊ីចំណីគ្រាប់(កូនត្រីមានអាយុមួយខែ) ត្រូវបានគេផ្សាំក្នុងស៊ងនៅក្នុងស្រះ
- ដង់ស៊ីតេស្តុកប្រហែល 5000ក្បាល/$m^3$
- ពេលស្តុកបានមួយអាទិត្យដំបូង ចំណីទំហំ1mm ត្រូវបានផ្តល់អោយត្រីស៊ី
- ទំហំចំណីដែលមានការកើនឡើងស្របទៅនឹងកំណើនទំងន់របស់ត្រី
- កូនត្រីត្រូវតែរែងជារៀងរាល់5-7ថ្ងៃម្តង



# ការគ្រប់គ្រងសុខភាពត្រី

# ប្រភេទជំងឺដែលកើតមានក្នុងពេលផ្សាំកូនត្រី

- បាក់តេរីវីប្រ៊ីអូរ ( *Vibrio spp.* )
  - *Vibrio anguillarum, V. Harvery and Vibrio spp. etc.*
  - វីប្រ៊ីអូរជាជំងឺដែលតែងតែកើតមាននៅពេលកូនត្រីមានអាយុប្រហែលពីរសប្តាហ៍ ដែលបណ្តាលអោយត្រីងាប់ច្រើន
  - វីប្រ៊ីអូរអាចបណ្តាលអោយត្រីងាប់ នៅពេលដែលមានចំនួនច្រើននៅក្នុងទឹក (10,000,000ក្បាល/មីលីលីត្រ)
  - ភាគច្រើនជាពពួកជំងឺឱកាសនិយម(ពពួកទាំងនេះមានវត្តមាននៅគ្រប់ទីកន្លែង)
  - រោគសញ្ញា ហែលយឺតៗ មិនសូវចាប់ចំណី ខ្លួនមានពណ៌ក្រហម ភ្នែកឡើងពណ៌ស និងមានឈាម ភ្នែកលៀនចេញក្រៅ
  - អាចការពារបានដោយប្រើ ពពួកបាក់តេរីមានប្រយោជន៍(Probiotic)
  - អាចព្យាបាលបានដោយប្រើ OTC (Oxytetracycline)



បណ្តុះបាក់តេរីដោយចាហួយ(TCBS)



នៅលើខ្លួនត្រីមានពណ៌ក្រហមនិងចេញឈាម



ភ្នែកត្រីលៀនចេញក្រៅ

- ជំងឺអុិចស *White spot disease*
  - Cryptocaryon irritans(Ciliata)
  - ជំងឺអុិចសច្រើនកើតមាននៅលើកូនត្រីចាប់ពីអាយុមួយខែឡើងទៅ
  - ជំងឺអុិចសឆ្លងនៅលើស្បែក ព្រុយ និងស្ទិតស្រកី
  - ឆ្លងទៅស្រកី ធ្វើអោយត្រីងាប់
  - រោគសញ្ញា មានអុិចពណ៌សនៅលើដងខ្លួន រលាកស្បែក ត្រដុសខ្លួនទៅនឹងសាច់បែរ ឬអាង មិនសូវចាប់ចំណី ហែលឃើតៗនៅលើផ្ទៃខាងលើ ឬផ្ទៃកបាត ហែលផ្តុំគ្នា
  - ការការពារនឹងការព្យាបាលទាន់ពេលអាចកាត់បន្ថយការងាប់របស់ត្រីបាន
  - ដាក់$H_2O_2$ ក្នុងអាងកូនត្រីក្នុងកម្រិត12 ppm រយៈពេល 4ថ្ងៃ
  - ឬដាក់ទងដែងស៊ុលផាត 01ppm ($CuSo_4$) នៅក្នុងអាងផ្សាំរយៈពេល 4ថ្ងៃ
  - ដាក់ស្ពាន់ខ្សែភ្លើងនៅក្នុងស្រះ ឬ បែរគ្រប់ពេល



កើតមាននៅលើស្បែកនឹងព្រុយ



កើតមាននៅលើស្និតស្រកី

# វដ្តជីវិតនៃ *Cryptocariyon irritans*




៣៥

# ប្រភេទចៃ( ប៉ារ៉ាស៊ីត )តោងនៅលើខ្លួនត្រី



# ប្រភេទថៃ បាក់តេរី ប៉ារ៉ាស៊ីត និងការព្យាបាល

| ប្រភេទ | ទីតាំងវាយលុក | ការព្យាបាល |
|---|---|---|
| *Vibrio spp.* | ពោះវៀន | ត្រាំជាមួយOTCក្នុងករណីផ្ទុះជំងឺនិងការពារដោយប្រើបាក់តេរីមានប្រយោជន៍ |
| *Cryptocaryon spp.* | ខ្លួន ព្រុយ ស្បែកនិងស្រកី | ត្រាំជាមួយទងដែងស៊ុលផាត 01ppm ឬ $H_2O_2$ 12 ppm រយៈពេល4ថ្ងៃ |
| *Trichodina spp.* | ខ្លួន និងស្រកី | ត្រាំជាមួយទងដែងស៊ុលផាត 01ppm ឬ ហ្វ័រម៉ាលីន 100ppm |
| *Gill fluke* | ស្អិតស្រកី | ត្រាំជាមួយទងដែងស៊ុលផាត 01ppm ឬ ហ្វ័រម៉ាលីន 100ppm រយៈពេល24ម៉ោង |
| *Skin fluke* | ខ្លួន | ត្រាំជាមួយទងដែងស៊ុលផាត 01ppm ឬ ហ្វ័រម៉ាលីន 100ppm រយៈពេល24ម៉ោង |
| *Caligus spp.* | ខ្លួន | ត្រាំជាមួយទងដែងស៊ុលផាត 01ppm ឬ ហ្វ័រម៉ាលីន 100ppm រយៈពេល24ម៉ោង |

# សូមអរគុណ!



